**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សុន្ទរកថា**
**ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**ថ្លែងក្នុងឱកាសបើក**
**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២**
**នៅសាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី**
**ថ្ងៃព្រហស្បតិ៍ ២កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦**
**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២**

- សូមគោរពអង្គពិធីទាំងមូល
- ឯកឧត្តម លោកជំទាវ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋានរាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!

’ ថ្ងៃនេះខ្ញុំពិតជាមានកិត្តិយស និងក្តីសោមនស្សក្រៃលែងដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ **“កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២”** ក្រោយពីខកខាន មិនបានជួបជុំគ្នាដោយផ្ទាល់ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៩ មកដោយសារការគំរាមកំហែងពីជំងឺកូវីដ១៩ ដែលបានបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាព នយោបាយ សុខភាពសាធារណៈ សេដ្ឋកិច្ចសង្គម ក្នុងទូទាំងពិភពលោក ។ មកទល់ពេលនេះ ស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩ ក្នុងព្រះរាជាណាចក្រកម្ពុជារបស់យើង បានធ្លាក់ចុះនិងថមថយយ៉ាងខ្លាំង ដែលអនុញ្ញាតឱ្យកម្ពុជាយើង បើកប្រទេសនិងសេដ្ឋកិច្ចជាតិឡើងវិញ ឈានទៅរកប្រក្រតីភាពស្ទើរទាំងស្រុង ។ ការបើកប្រទេស និងសេដ្ឋកិច្ចជាតិឡើងវិញនេះ បានទទួលការអបអរសាទរ ពីប្រជាជនយើងទាំងមូល និងការកោតសរសើរពីគ្រប់មជ្ឈដ្ឋាន។ ទោះជាកូវីដ-១៩ មិនទាន់រលាយបាត់អស់យ៉ាងណាក៏ដោយ ក៏ជ័យជម្នះកន្លងមកដែលកម្ពុជាយើងទទួលបានក្នុងការគ្រប់គ្រងជំងឺរាតត្បាតនេះ បានបង្ហាញឱ្យយើង

ឃើញនូវភាពដឹកនាំ ដ៏មានប្រសិទ្ធភាពខ្ពស់ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន** ជាប្រមុខ ។ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់**សម្តេចតេជោ** កម្ពុជាយើងត្រូវបានទទួលស្គាល់ថា ជាប្រទេសដ៏ឆ្នើមមួយក្នុងពិភពលោក ដែលបានទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ បានយ៉ាងល្អបំផុតតាមរយៈការចាក់វ៉ាក់សាំង ស្រោចដល់ប្រជាពលរដ្ឋរបស់ខ្លួន ក្នុងអត្រាខ្ពស់បំផុត ។ ជាមួយនោះក្នុងរយៈពេល២ឆ្នាំ កន្លងទៅ ទោះបីជាត្រូវប្រឈមនឹងគ្រោះមហន្តរាយ ដែលកើតឡើងដោយការរាតត្បាតនៃជំងឺកូវីដ-១៩ក៏ដោយ ក៏កម្ពុជាយើងនៅរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសុខុមាលភាពសង្គមយ៉ាងរឹងមាំ ។ ក្នុងនាមអង្គប្រជុំពេញអង្គ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមអបអរសាទរចំពោះលទ្ធផលដ៏ប្រពៃនេះ និងសូមសម្តែងនូវកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះ**សម្តេចតេជោ** ដែលបានដឹកនាំយើងទាំងអស់គ្នាឱ្យរួចចាកពីមហន្តរាយនៃគ្រោះកូវីដ-១៩។ ជាក់ស្តែងក្នុងរយៈពេលជិតពីរខែកន្លងទៅនេះ កម្ពុជាយើងមិនមានអ្នកឆ្លងថ្មីណាម្នាក់ឡើយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា** !

ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គដោយផ្ទាល់ លើកទីមួយសម្រាប់ឆ្នាំ២០២២ នាពេលនេះ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ ដែលបានខិតខំប្រឹងប្រែង ចូលរួមអនុវត្តការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍យ៉ាងសកម្ម រហូតទទួលបានលទ្ធផលជាផ្លែផ្កា គួរជាទីមោទនៈ។ តាមរបាយការណ៍របស់អង្គការ UNAIDS ចេញផ្សាយកាលពីឆ្នាំ២០២១ អត្រាគ្របដណ្តប់នៃសេវាព្យាបាលអេដស៍នៅកម្ពុជា មានអត្រាខ្ពស់ជាងគេនៅតំបន់អាស៊ីប៉ាស៊ីហ្វិក គឺខ្ពស់ជាងប្រទេសថៃ ប្រទេសចិន និងប្រទេសវៀតណាម ។ យើងត្រូវរួបរួមគ្នា ខិតខំថែមទៀត ដើម្បីស្វែងរកអ្នកផ្ទុកមេរោគអេដស៍ប្រមាណជា **១២.០០០ នាក់** ដែលបាត់មុខមិនទាន់មកទទួលសេវាព្យាបាល ដើម្បីយើងអាចឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ ទាំងស្រុងនៅឆ្នាំ២០២៥ ។ ជាមួយគ្នានោះ យើងត្រូវខិតខំអនុវត្ត ឱ្យកាន់តែជាក់ស្តែងថែមទៀត នូវសេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីវិធានការ ៦ចំណុច ដើម្បីពង្រឹងប្រព័ន្ធជាតិ ( Country System ) ក្នុងការឆ្លើយតបជា ពហុវិស័យ ចំពោះការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ឈានទៅសម្រេចឱ្យបាន ក្នុងពេលឆាប់ៗនូវចីរភាពនៃកម្មវិធីអេដស៍នៅកម្ពុជា ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមវាយតម្លៃខ្ពស់ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានជួយគាំទ្រគោលនយោបាយជាតិរបស់យើងដោយបានដាក់ចេញ នូវនីតិវិធីជាតិ សម្រាប់ប្រើប្រាស់

ថវិកាជាតិនៅថ្នាក់ក្រោមជាតិ និងផ្ដល់ថវិកាសម្រាប់ការងារអេដស៍ ដល់ក្រសួង និងស្ថាប័ន ពាក់ព័ន្ធ ទោះជាក្នុងកម្រិតណាក៏ដោយ ដែលនេះជាកត្តាមិនអាចខ្វះបាន ដើម្បីសម្រេចគោលដៅលុបបំបាត់ជំងឺ អេដស៍ឱ្យអស់នៅឆ្នាំ២០២៥ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

ខ្ញុំសូមជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា យោងតាមគម្រោងផែនការសកម្មភាពឆ្នាំ២០២២ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ធ្វើឡើងដើម្បីពិនិត្យមើលរួមគ្នានូវ វឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់រយៈពេល៦ខែដើមឆ្នាំ ២០២២ និងធ្វើការប្រមូល និងពិភាក្សាលើ ធាតុចូល និងអនុសាសន៍មួយចំនួន តាមរយៈការចូលរួម របស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញាដែលមានវត្តមានក្នុងពេលនេះ។

តាមរបៀបវារៈកិច្ចប្រជុំ យើងនឹងមានបទបង្ហាញចំនួនបី រួមមាន ៖

- ទី១ បទបង្ហាញស្ដីពី របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រលើកទី៥ បង្ហាញ ជូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹង ជំងឺអេដស៍។
- ទី២ បទបង្ហាញស្ដីពីការរៀបចំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបង្ការ នៃការចម្លងមេរោគអេដស៍ ជាសកល បង្ហាញជូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញា ធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ទី៣ បទបង្ហាញស្ដីពីការសម្របសម្រួលបញ្ចប់អេដស៍ឆ្នាំ២០២៥ បង្ហាញជូនដោយ **ឯកឧត្តម វេជ្ជបណ្ឌិត ទា ផលា** អនុប្រធាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

បន្ទាប់មក យើងនឹងមានការពិភាក្សារួមគ្នា និងដាក់ចេញនូវសេចក្ដីសម្រេចចិត្តកិច្ចប្រជុំ ពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមទាញអារម្មណ៍កិច្ចប្រជុំពេញអង្គថា យើងបាន និងកំពុងតែធ្វើ ដំណើររួមគ្នាប្រកបដោយទស្សនវិស័យច្បាស់លាស់ក្នុងក្ដីសង្ឃឹមពិតប្រាកដ ឆ្ពោះទៅរកការលុបបំបាត់ ជំងឺអេដស៍ក្នុងពេលដ៏ខ្លីខាងមុខ ។ យើងមានក្ដីសង្ឃឹម ដោយសារតែយើងទទួលបាន នូវការប្ដេជ្ញាចិត្ត និងការគាំទ្រនយោបាយដ៏រឹងមាំរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោហ៊ុនសែន** នាយករដ្ឋ មន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ រួមគ្នា យើងនឹងកសាងបាននូវចីរភាព នៃការឆ្លើយតបជាពហុវិស័យ

ទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងជាពិសេសបណ្តាញអ្នកផ្ទុកមេរោគអេដស៍ ។ ទាំងអស់គ្នា យើងបង្កើតបាននូវ ស្ថាប័នដឹកនាំគ្រប់គ្រងនិងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជាពិសេស យើងមានផែនការយុទ្ធសាស្រ្តជាតិតែមួយ មានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**!

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមានសារៈសំខាន់ដែលនឹងផ្តល់ទៅដល់ក្រុមការងារបច្ចេកទេស អាចយកទៅប្រើប្រាស់ក្នុងការបន្តអនុវត្តការងារឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងពេលខាងមុខ ឱ្យស្របទៅតាមអនុសាសន៍និងសេចក្តីសម្រេចចិត្ត ដែលនឹងផ្តល់ជូន និងដាក់ចេញដើម្បីអនុម័តក្នុងកិច្ចប្រជុំពេញអង្គ នាពេលបន្តិចទៀតនេះ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ការងារពីបណ្តាសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំនាពេលនេះតែប៉ុណ្ណេះ។

ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងប្រាជ្ញាវាងវៃ ដើម្បីចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២** " ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**!